# ស្វែងយល់ទស្សនៈសាធារណជនចំពោះការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា ៖ សេចក្តីសង្ខេបពីការស្រាវជ្រាវ

ខែមករា ឆ្នាំ២០១១

## សេចក្តីផ្តើម

តាមរយៈបទពិសោធន៍ពីបណ្តាប្រទេសនានាជុំវិញពិភពលោក បានឱ្យដឹងថាការលើកកំពស់ការយល់ដឹងជាសាធារណៈពីការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាប្រឈមជាពិសេសសំរាប់ប្រទេសដូចជា ប្រទេសកម្ពុជា ដែលប្រជាជនប្រមាណជាង៨០% មានជីវភាពពឹងផ្អែកលើកសិកម្មចិញ្ចឹមជីវិត និងជាអ្នកងាយរងគ្រោះពីល័ក្ខខ័ណ្ឌនៃការប្រែប្រួលអាកាសធាតុ។ អាស្រ័យហេតុនេះ ក្រសួងបរិស្ថានរបស់ប្រទេសកម្ពុជាបានប្រគល់ការសិក្សាមួយមកឱ្យអង្គការ ប៊ីប៊ីស៊ីបំរើពិភពលោក ដើម្បីសិក្សាស្វែងយល់ពីទស្សនៈរបស់សាធារណជនជុំវិញបញ្ហាការប្រែប្រួលអាកាសធាតុ និងដើម្បីផ្តល់អនុសាសន៍ ជាគំរោងផែនការផ្សព្វផ្សាយ និងផ្តល់ព័ត៌មាននាពេលអនាគត។

ក្នុងឆ្នាំ២០១០ ក្រុមសិក្សាស្រាវជ្រាវរបស់អង្គការ ប៊ីប៊ីស៊ីបំរើពិភពលោក បានធ្វើការស្រាវជ្រាវមួយទូទាំង២៤ខេត្ត-ក្រុងក្នុងប្រទេសកម្ពុជា ដើម្បីស្វែងយល់ពីទស្សនៈរបស់សាធារណជនជុំវិញបញ្ហាការប្រែប្រួលអាកាសធាតុ។ ការសិក្សានេះ គឺជាការស្ទាបស្ទង់ទស្សនៈរបស់សាធារណជនកម្ពុជាចំនួន ២៤០១នាក់ ដែលជាតំណាងឱ្យប្រជាជនកម្ពុជាទាំងមូល ក្នុងនោះមានប្រជាជនមកពីសហគមន៍កសិកម្ម និងនេសាទ គ្រូបង្រៀន ពាណិជ្ជករ ស្ត្រីមេផ្ទះ និងមន្ត្រីរដ្ឋាភិបាល។ ការស្រាវជ្រាវនេះ បានធ្វើកិច្ចសំភាសន៍បែបស៊ីជំរៅជាមួយបុគ្គលសំខាន់ៗចំនួន ១០១នាក់ ដែលមកពីផ្នែកប្រព័ន្ធផ្សព្វផ្សាយ ឧស្សាហកម្ម មន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ខេត្ត បុគ្គលដែលមានប្រជាប្រិយភាព និងអ្នកដឹកនាំមូលដ្ឋាន (រួមមានអ្នកដឹកនាំក្រុមប្រឹក្សាឃុំ-សង្កាត់ មេភូមិ ចាស់ព្រឹទ្ធាចារ្យក្នុងភូមិ និងអ្នកដឹកនាំសាសនា)។

កម្ពុជាជាប្រទេសមួយដែលងាយរងគ្រោះពីផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ ប៉ុន្តែការស្រាវជ្រាវនេះបានបង្ហាញឱ្យឃើញថា ចំណេះដឹង និងការយល់ដឹងរបស់ប្រជាជនកម្ពុជាពីមូលហេតុ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ គឺមានកំរិតនៅឡើយ។ អនុសាសន៍ពីការសិក្សានេះនឹងជួយគាំទ្រ បណ្តាស្ថាប័ន និងបុគ្គលដែលពាក់ព័ន្ធ ដែលនឹងផ្តល់ព័ត៌មាន និងធនធានសមស្រប ដើម្បីជួយលើកកំពស់ការយល់ដឹង និងសមត្ថភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុរបស់ប្រជាជន។

## លទ្ធផលសំខាន់ៗនៃការសិក្សា

ប្រជាជនកម្ពុជានិយាយថា ធាតុអាកាស និងបរិស្ថានរបស់ពួកគេកំពុងតែប្រែប្រួល ហើយពួកគេមានអារម្មណ៍ថាកំពុងតែទទួលរងឥទ្ធិពលពីការប្រែប្រួលនេះ។ ពួកគេក៏បានឱ្យដឹងទៀតថា បណ្តាគ្រោះធម្មជាតិ ជាពិសេសគ្រោះរាំងស្ងួត កំពុងកើតមានជាញឹកញាប់ និងធ្ងន់ធ្ងរជាងសព្វមួយដង ហើយសីតុណ្ហភាពក៏ចេះតែកើនឡើង។

អ្នកឆ្លើយតបស្ទើរតែគ្រប់រូបធ្លាប់ជួបប្រទះគ្រោះធម្មជាតិ យ៉ាងហោចណាស់ម្តង ក្នុងរយៈពេល ១ឆ្នាំកន្លងមក ហើយជាង ១ ភាគ ៣ នៃអ្នកឆ្លើយតប មិនបានទទួលព័ត៌មានពីគ្រោះធម្មជាតិដែលពួកគេជួបប្រទះនោះទេ។ ៧៥% នៃអ្នកដែលបានទទួលព័ត៌មាន គឺទទួលបានព័ត៌មានក្នុងកំឡុងពេល ឬក៏ក្រោយពេលហេតុការណ៍បានកើតឡើងហើយ។

**"ខ្ញុំមិនដឹងថាត្រូវការធនធានអ្វីទេ ព្រោះខ្ញុំអត់យល់ពីការប្រែប្រួលអាកាសធាតុផង។ ខ្ញុំគិតថាធនធានដែលសំខាន់បំផុត គឺចំណេះដឹង។"**

**ប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់**



មួយភាគធំនៃសេដ្ឋកិច្ចកម្ពុជា គឺពឹងផ្អែកលើវិស័យកសិកម្ម ដែលនេះធ្វើឱ្យប្រទេសកម្ពុជាងាយរងគ្រោះពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

UNDP/ARANTXA CEDILLO 2010

អ្នកឆ្លើយតប ទូទាំងប្រទេសកម្ពុជា ភាគច្រើននិយាយថាពួកគេធ្លាប់ឮពាក្យ "ការប្រែប្រួលអាកាសធាតុ" (៨៤%) ឬក៏ "ការឡើងកំដៅផែនដី" (៧០%)។ អ្នកឆ្លើយតបភាគច្រើន និយាយថាពួកគេឮពាក្យទាំងពីរនេះ មកពីប្រព័ន្ធផ្សព្វផ្សាយ ឬការនិយាយតៗគ្នា។ ពួកគេបានពន្យល់ពាក្យទាំងពីរនេះ តាមរយៈការសង្កេតរបស់ពួកគេពីការប្រែប្រួលដូចជា អ្នកឆ្លើយតបភាគច្រើន បានបកស្រាយពាក្យ "ការប្រែប្រួលអាកាសធាតុ" ដោយផ្សារភ្ជាប់ជាមួយនឹង ជំងឺបញ្ហាដំាដុះ គ្រោះរាំងស្ងួត កំណើនសីតុណ្ហភាព ទិន្នផលធ្លាក់ចុះ និងកង្វះទឹកប្រើប្រាស់។ ពួកគេនិយាយថាធាតុអាកាសប្រែប្រួល បានជះឥទ្ធិពលលើការងាររបស់ពួកគាត់ ហើយអ្នកឆ្លើយតបភាគច្រើនបានលើកឡើងពីកង្វះខាតទឹកសំរាប់ការងាររបស់ពួកគេ។ អភិបាលខេត្តមួយរូបមានប្រសាសន៍ថា "ជាធម្មតានៅខែកក្កដាហ្នឹង យើងមានទឹកបរិបូណ៌ណាស់សំរាប់ធ្វើស្រែ...ប៉ុន្តែឥឡូវនេះ បើយើងសង្កេតមើល យើងអាចនិយាយបានថា មានស្រែតិចតួចណាស់ត្រូវបានស្ទូង ហើយមួយចំនួននោះបានស្ទូងលើដីគោក យើងមិនមានទឹកគ្រប់គ្រាន់ ដូចនេះប្រជាជនមិនអាចធ្វើស្រែចំការបានទេ។ ប្រជាជនមានជំងឺ... ការប្រែប្រួលហ្នឹង ធ្វើឱ្យយើងឈឺ។ ការប៉ះពាល់ទាំងនេះបានទាញប្រជាជនទៅរកភាពក្រីក្រ។"

មានអ្នកឆ្លើយតបតិចតួចណាស់ ដែលបានពន្យល់ការប្រែប្រួលធាតុអាកាស ដោយផ្សារភ្ជាប់ទៅនឹងការបំពុលចេញពីរោងចក្រឧស្សាហកម្ម ឬការប្រើប្រាស់យានជំនិះ។ បុគ្គលសំខាន់ៗជាច្រើន ជាពិសេសអ្នកនៅថ្នាក់មូលដ្ឋានមិនយល់ ហើយហាក់ដូចជាមានការភាន់ច្រឡំលើប្រធានបទ ការប្រែប្រួលអាកាសធាតុនេះ ដូចដែលមេភូមិ ១រូបបានពន្យល់ថា " វាក្តៅ ផែនដីឡើងក្តៅខ្លាំង។ ខ្ញុំគិតថាផែនដីកាន់តែស្តើងទៅៗ ហើយអាចផ្ទុះឡើង។ ខ្ញុំមិនសូវច្បាស់ប៉ុន្មានទេរឿងនេះ។"

អ្នកឆ្លើយតបភាគច្រើន មិនបានពន្យល់មូលហេតុការប្រែប្រួលធាតុអាកាស ថាមកពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាសកលនោះទេ ប៉ុន្តែពួកគេបានពន្យល់ថាមកពីការកាប់បំផ្លាញព្រៃឈើនៅក្នុងប្រទេសកម្ពុជា។ ២ ភាគ ៣ នៃអ្នកឆ្លើយតប (៦៧%) គិតថា ការកាប់បំផ្លាញព្រៃឈើនេះគឺ ជាមូលហេតុដែលធ្វើ

## វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះ បានប្រើវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ និងបរិមាណវិស័យ។

ក្រុមអ្នកស្រាវជ្រាវ បានធ្វើកិច្ចសំភាសន៍បែបស៊ីជំរៅជាមួយបុគ្គលសំខាន់ៗចំនួន ១០១នាក់ ដែលជាតំណាងមកពីប្រព័ន្ធផ្សព្វផ្សាយ ឧស្សាហកម្ម មន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ និងអភិបាលខេត្ត បុគ្គលដែលមានប្រជាប្រិយភាព និងអ្នកដឹកនាំថ្នាក់មូលដ្ឋាន (ប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ មេភូមិ ចាស់ព្រឹទ្ធាចារ្យ និងមេដឹកនាំសាសនា)។ កិច្ចសំភាសន៍ទាំងអស់ត្រូវបានកត់ត្រា ហើយក្រុមអ្នកស្រាវជ្រាវបានប្រើកម្មវិធី Atlas.ti ដើម្បីប្រមូល ផ្តុំចំលើយនៅក្នុងអត្ថបទកត់ត្រាទាំងនោះ ហើយយកមកវិភាគគំនិតសំខាន់ៗដែលមានក្នុងទិន្នន័យបែបគុណវិស័យ។

ក្រុមអ្នកស្រាវជ្រាវបានប្រើកំរងបញ្ជីសំណួរដើម្បីប្រមូលទស្សនៈយល់ឃើញរបស់សាធារណជន ពីបុគ្គលចំនួន ២៤០១នាក់ នៅក្នុង ២៤ខេត្ត-ក្រុង។ បុគ្គលដែលចូលរួមឆ្លើយតបនឹងកំរងបញ្ជីសំណួរ គឺមានអាយុចាប់ពី ១៥ ដល់ ៥៥ឆ្នាំ ហើយភាគច្រើននៃពួកគេមានកំរិតជីវភាពស្ថិតក្នុងភាពងាយទទួលរងគ្រោះថ្នាក់ពីឥទ្ធិពលការប្រែប្រួលអាកាសធាតុ។ ក្រុមអ្នកស្រាវជ្រាវបានធ្វើការជ្រើសរើសភូមិជាសំណាកតាមរបៀបប្រូបាប៊ីលីតេតាមសមាមាត្រនៃទំហំ និងអ្នកផ្តល់បទសំភាសន៍បញ្ជីសំណួរដោយរបៀបចៃដន្យ។

ក្រុមអ្នកស្រាវជ្រាវ បានប្រើកម្មវិធី SPSS ដើម្បីវិភាគទិន្នន័យបរិមាណបែបវិស័យ។ វិធីសាស្ត្រវិភាគគឺតាមបែបបកស្រាយ និងការប្រៀបធៀបភាពខុសគ្នារវាងក្រុមនីមួយៗ នឹងចំណេះដឹង ឥរិយាបថ និងការអនុវត្ត ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។

ការបកស្រាយលំអិតពីវិធីសាស្ត្រស្រាវជ្រាវ គឺមាននៅក្នុងរបាយការណ៍។

គេហទំព័រ www.camclimate.org.kh

# ស្វែងយល់ទស្សនៈសាធារណជនចំពោះការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា



BBC WST 2010

៩៣% នៃប្រជាជនកម្ពុជាបានជួបប្រទះគ្រោះធម្មជាតិយ៉ាងហោចណាស់ ១ កាលពីឆ្នាំកន្លងទៅ

ឱ្យធាតុអាកាសប្រែប្រួល ។ ការកាប់បំផ្លាញព្រៃឈើក៏ជាកង្វល់មួយសំរាប់បុគ្គលសំខាន់ៗដោយ ពួកគាត់យល់ឃើញថា ដើមឈើដើរតួនាទីទាក់ទាញទឹកភ្លៀង រក្សាទឹកក្រោមដី ហើយការពារមនុស្សឱ្យរួចផុតពីការបំផ្លិចបំផ្លាញដោយខ្យល់ព្យុះ និងទឹកជំនន់ ។

ប្រជាជនមិនប្រាកដថា ការប្រែប្រួលអាកាសធាតុដែលពួកគេធ្លាប់ជួបប្រទះ នឹងបន្តជះឥទ្ធិពលទៅលើពួកគេ ក្នុងរយៈពេលវែងនោះទេ ។ អ្នកឆ្លើយតប ៨៤% ដែលធ្លាប់ឮពាក្យ "ការប្រែប្រួលអាកាសធាតុ" បានឱ្យដឹងថា ការប្រែប្រួលអាកាសធាតុឥឡូវនេះកំពុងជះឥទ្ធិពលមកលើប្រទេសកម្ពុជា ។ បើទោះបីជា ៧៥% នៃពួកគេ គិតថាការប្រែប្រួលអាកាសធាតុនឹងជះឥទ្ធិពលមកលើប្រទេសកម្ពុជានាពេលអនាគតក៏ដោយ ក៏ជាង ១ ភាគ ៥ នៃពួកគេ (២២%) និយាយថា ពួកគេមិនដឹងថា តើកម្ពុជានឹងទទួលផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដែរឬទេ នៅថ្ងៃអនាគត ។

ការយល់មិនបានច្បាស់ពីពាក្យ "ការប្រែប្រួលអាកាសធាតុ" និង "ការប្រែប្រួលធាតុអាកាស" អាចធ្វើឱ្យប្រជាជនមិនអាចបកស្រាយ ការប្រែប្រួលអាកាសធាតុជាសកលថាជាផលប៉ះពាល់រយៈពេលវែងនោះទេ ដោយហេតុថាពាក្យខ្មែរ "ការប្រែប្រួលអាកាសធាតុ" និង "ការប្រែប្រួលធាតុអាកាស" (គឺថា "អាកាសធាតុ" និង "ធាតុអាកាស") គឺស្រដៀងគ្នាមែនទែន ។ អាស្រ័យហេតុនេះ ប្រជាជនអាចយល់ថាពាក្យ "ការប្រែប្រួលអាកាសធាតុ" ថាជា "ការប្រែប្រួលធាតុអាកាស" ដែលនេះ គឺមានសារៈសំខាន់ណាស់ ដោយហេតុថា "ការប្រែប្រួលធាតុអាកាស" គឺសំដៅទៅលើការប្រែប្រួលធាតុអាកាសក្នុងរយៈពេលខ្លីប៉ុណ្ណោះ ចំណែកឯ "ការប្រែប្រួលអាកាសធាតុ" គឺសំដៅទៅលើការប្រែប្រួលធាតុអាកាសក្នុងរយៈពេលវែង ។

> **"យើងមិនមានទឹកគ្រប់គ្រាន់ ដូចនេះប្រជាជនមិនអាចធ្វើស្រែចំការបានទេ។ ការប៉ះពាល់ទាំងនេះ បានទាញប្រជាជនទៅរកភាពក្រីក្រ។"**
>
> **អភិបាលខេត្ត**

ភាពមិនប្រាកដនេះ ជាកត្តាជំរុញឱ្យមានយុទ្ធសាស្ត្រទប់ទល់នឹងផលប៉ះពាល់នៃការប្រែប្រួលធាតុអាកាសមកលើអាយុជីវិត និងជីវភាពរបស់ប្រជាជន ។ បុគ្គលសំខាន់ៗជាច្រើនបានឱ្យដឹងថា សហគមន៍ជនបទដែលងាយរងគ្រោះបំផុត ត្រូវការការគាំទ្រដើម្បីរៀបចំបង្កើតឱ្យមានយុទ្ធសាស្ត្រសមស្របរយៈពេលវែង ។

១ ភាគ ៤ នៃអ្នកឆ្លើយតប និយាយថាពួកគេមិនដឹងថាត្រូវទប់ទល់នឹងធាតុអាកាសប្រែប្រួលយ៉ាងណានោះទេ ។ វិធានការឆ្លើយតបដែលមានក្នុងពេលបច្ចុប្បន្ននេះ ទំនងជាមានរយៈពេលខ្លីតែប៉ុណ្ណោះ ។ អ្នកឆ្លើយតប ៥៩% គិតថា សព្វថ្ងៃនេះ ពួកគេមិនអាចទប់ទល់នឹងធាតុអាកាសប្រែប្រួលនោះបានទេ ហើយពួកគេ (៥២%) ក៏បានលើកឡើងផងដែរថា ពួកគេមិនបានទទួលព័ត៌មានដែលពួកគេត្រូវការដើម្បីទប់ទល់នោះទេ ។ ឧបសគ្គបីសំខាន់បំផុត គឺកង្វះខាតថវិកា កង្វះ ខាតសំភារៈ និងកង្វះខាត ព័ត៌មាន ។

លទ្ធផលការស្រាវជ្រាវគុណវិស័យ និងបរិមាណវិស័យនេះ បានបង្ហាញឱ្យឃើញថា នារីច្រើនជាងបុរស អ្នកជនបទច្រើនជាងអ្នកទីក្រុង ប្រជាជនក្រីក្រ និងអ្នកមានកំរិតវប្បធម៌ទាបបំផុត ខ្វះនូវព័ត៌មានដែលពួកគេត្រូវការដើម្បីទប់ទល់នឹងធាតុអាកាសប្រែប្រួល ។ តាមរយៈយោបល់របស់មេភូមិ និងប្រធានក្រុមប្រឹក្សាឃុំ/ សង្កាត់ ក៏បានឆ្លុះបញ្ចាំងលទ្ធផលការសិក្សានេះជាពិសេសដែរ ។ សំរាប់ពួកគេ ព័ត៌មានអាចជាធនធានដ៏សំខាន់បំផុត ដូចដែលប្រធានក្រុមប្រឹក្សាឃុំម្នាក់បានមានប្រសាសន៍ថា "ខ្ញុំមិនដឹងថាត្រូវការធនធានអ្វីនោះទេ ព្រោះខ្ញុំអត់យល់ពីការប្រែប្រួលអាកាសធាតុផង ។ ខ្ញុំគិតថាធនធានដែលសំខាន់បំផុតគឺចំណេះដឹង ។"

ការផ្សព្វផ្សាយព័ត៌មានដែលពាក់ព័ន្ធនៅពេលវេលាដែលត្រឹមត្រូវ នឹងជួយប្រជាជនកម្ពុជាអាចទប់ទល់នឹងការប្រែប្រួលអាកាសធាតុជាសកលបាន ។ ប្រជាជនកម្ពុជាយល់ឃើញថា រដ្ឋាភិបាល នាយករដ្ឋមន្ត្រី និងអង្គការក្រៅរដ្ឋាភិបាល ជាអ្នកត្រូវចេញមុខដឹកនាំដោះស្រាយបញ្ហានេះ ។ ប៉ុន្តែប្រជាជននៅមិនទាន់ដឹងច្បាស់ថា តើបុគ្គល ឬក៏អង្គភាពណាមួយដែលធ្វើការពាក់ព័ន្ធនឹងបញ្ហានេះ ហើយពួកគេក៏បានបន្ថែមទៀតថា ពួកគេមិនបានដឹងថាមានកម្មវិធីជាតិ និងកម្មវិធីមូលដ្ឋានណាខ្លះឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនោះទេ ។

ដូចនេះ ប្រជាជនភាគច្រើន កំពុងតែធ្វើការសំរេចចិត្តពីរបៀបដែលពួកគេត្រូវទប់ទល់នឹងការប្រែប្រួលអាកាសធាតុដោយពុំទទួលបានព័ត៌មាន ឬក៏ពុំមានការគាំទ្រពីប្រភពណាមួយ ក្រៅពីសហគមន៍របស់ពួកគេនោះទេ ។ បុគ្គលសំខាន់ៗ ជាច្រើនចង់ឱ្យមានការផ្តល់ព័ត៌មានពីបញ្ហានេះទៅដល់សហគមន៍ ។ មេភូមិ ប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ និងមេដឹកនាំសាសនា គឺមិនទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ អំពីបញ្ហានេះដូចមន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិនោះទេ ។

## អនុសាសន៍

- ត្រូវទទួលស្គាល់ថា ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាស្មុគស្មាញ ហើយប្រជាជន មានការយល់ដឹងពីពាក្យ "ការប្រែប្រួលអាកាសធាតុ" នៅតិចតួចនៅឡើយ ។ ត្រូវធ្វើយ៉ាងណាឱ្យសារដែលត្រូវផ្សព្វផ្សាយមានលក្ខណៈសាមញ្ញ និងមានន័យគ្រប់គ្រាន់ ដើម្បីជៀសវាងធ្វើឱ្យអ្នកដឹកនាំតាមមូលដ្ឋាន និង សាធារណជនទូទៅមានការភាន់ច្រឡំ ។
- ត្រូវពន្យល់ប្រជាជនឱ្យដឹងថា ការប្រែប្រួលអាកាសធាតុមានផលប៉ះពាល់រយៈពេលវែង ។ ដំណោះស្រាយដែលមានប្រសិទ្ធភាព គឺការផ្សព្វផ្សាយពីការប្រែប្រួលអាកាសធាតុ ដែលសមស្របទៅនឹងបទពិសោធន៍របស់ប្រជាជនកម្ពុជា ។
- រៀបចំបង្កើតឱ្យមានការផ្សព្វផ្សាយពីការប្រែប្រួលអាកាសធាតុ តាមរយៈប្រភពព័ត៌មានដែលប្រជាជនកម្ពុជាប្រើ និងជឿទុកចិត្ត ដូចជាទូរទស្សន៍ វិទ្យុ និងការនិយាយពីមាត់មួយទៅមាត់មួយ ។ ប្រើទូរស័ព្ទដៃដើម្បីជំរុញការទំនាក់ទំនងគ្នាពីបុគ្គលមួយទៅបុគ្គលមួយ ។
- កាត់បន្ថយគំលាតរវាងយុទ្ធសាស្ត្រត្រៀម និងគ្រោះមហន្តរាយដែលនឹងកើតមាន និងគំលាតរវាងយុទ្ធសាស្ត្រទប់ទល់ និងគ្រោះមហន្តរាយដែលនឹងកើតមាន តាមរយៈយុទ្ធសាស្ត្រការផ្សព្វផ្សាយពីការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ ។ យុទ្ធសាស្ត្រនេះ នឹងជួយកាត់បន្ថយចំនួនប្រជាជនដែលមិនទទួលបានព័ត៌មានអំពីគ្រោះធម្មជាតិ ដែលនឹងអាចជះឥទ្ធិពលទៅលើពួកគេ ដោយបង្កើននូវចំនួនអ្នកទទួលបានព័ត៌មានមុនពេលហេតុការណ៍កើតឡើង ។
- ផ្តល់ការគាំទ្រដល់សហគមន៍ នៅពេលដែលពួកគេទប់ទល់នឹងធាតុអាកាសប្រែប្រួល តាមរយៈការកែលំអប្រព័ន្ធផ្សព្វផ្សាយជាសាធារណៈស្តីអំពីចំណេះដឹងវិទ្យាសាស្ត្រ ។ បង្កើតឱ្យមានការអនុវត្តជាគំរូណាមួយនូវមូលដ្ឋានចំណេះដឹងវិទ្យាសាស្ត្រទាំងនេះ ដើម្បីកែលំអវិស័យ កសិកម្ម សុខភាព ការគ្រប់គ្រងធនធានទឹក និងកាត់បន្ថយហានិភ័យពីគ្រោះមហន្តរាយនានា ។
- លើកកំពស់ការយល់ដឹងជាសាធារណៈស្តីពីការប្រែប្រួលអាកាសធាតុសកល ដោយផ្អែកទៅលើបទពិសោធន៍របស់ប្រជាជនកម្ពុជា ។ ប្រើប្រព័ន្ធផ្សព្វផ្សាយ និងការផ្សព្វផ្សាយក្នុងទំរង់ចុះអប់រំតាមមូលដ្ឋាន ដើម្បីលើកទឹកចិត្តប្រជាជនឱ្យអនុវត្ត ចំណេះដឹងវិទ្យាសាស្ត្រតាមបែបបទពិសោធន៍របស់ពួកគាត់ ។ ផ្សព្វផ្សាយ និងបង្កើតឱ្យមានបច្ចេកទេសថ្មីៗ និងបច្ចេកវិទ្យាក្នុងប្រទេសកម្ពុជា និងពីបណ្តាប្រទេសដទៃទៀត លើសកលលោក ។

ក្រសួងបរិស្ថាន និងអង្គការប៊ីប៊ីស៊ី បំរើពិភពលោក សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ Oxfam កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំប្រទេសកម្ពុជា (UNDP) និងអង្គការ Danida ដែលឧបត្ថម្ភគាំទ្រដល់ការសិក្សាស្រាវជ្រាវនេះ ។ ក្រុមសិក្សាស្រាវជ្រាវនៃអង្គការប៊ីប៊ីស៊ីបំរើពិភពលោក សូមអរគុណចំពោះក្រុមអ្នកប្រមូលទិន្នន័យក្នុងការសិក្សានេះផងដែរ ។ ក្រសួងបរិស្ថាន ក៏សូមអរគុណចំពោះក្រុមអ្នកប្រមូលទិន្នន័យ និងក្រុមសិក្សាស្រាវជ្រាវរបស់អង្គការប៊ីប៊ីស៊ីបំរើពិភពលោក ។ ការវិភាគ និងការរៀបចំរបាយការណ៍ត្រូវបានធ្វើដោយក្រុមសិក្សាស្រាវជ្រាវនៃអង្គការ ប៊ីប៊ីស៊ី ប្រចាំប្រទេសកម្ពុជា និងចក្រភពអង់គ្លេស រួមមាន Miriam Burton ប៊ី វីរៈ ថែម វុទ្ធី ជីវ លីនណា Lizz Frost Yocum ហេង ភស្សត្តិ ត្រាក់ ពិសិដ្ឋ និង អ៊ុយ សារ៉េត ។ សេចក្តីសង្ខេបការស្រាវជ្រាវនេះ រៀបរៀងដោយ Miriam Burton ដោយមានការចូលរួមពី Ben Browett, Kirsty Cockburn និង Lizz Frost Yocum ។

អ្នកអានត្រូវបានលើកទឹកចិត្តឱ្យបន្តផលិត ឬដកស្រង់ចេញពីសេចក្តីសង្ខេបនេះ និងរបាយការណ៍ការសិក្សានេះ ប៉ុន្តែអង្គការ ប៊ីប៊ីស៊ី បំរើពិភពលោកសំណូមពរឱ្យមានដាក់អង្គការ ប៊ីប៊ីស៊ី បំរើពិភពលោកនៅក្នុងសេចក្តីថ្លែងអំណរគុណ និងសុំច្បាប់ថតចម្លងចំនួន ១ ច្បាប់ ។ សេចក្តីសង្ខេបការស្រាវជ្រាវនេះ ផលិតដោយ BBC និងអង្គការ ប៊ីប៊ីស៊ី បំរើពិភពលោក ហើយសេចក្តីសង្ខេបមិនគួរត្រូវបានយកទៅប្រើដើម្បីឆ្លុះបញ្ចាំងពីគោលនយោបាយរបស់ BBC នោះទេ។ រាល់កំហុសឆ្គងគឺជារបស់អ្នកនិពន្ធ។ ©ក្រសួងបរិស្ថាន ២០១០ ©អង្គការ ប៊ីប៊ីស៊ីបំរើពិភពលោក ២០១០

អង្គការប៊ីប៊ីស៊ី បំរើពិភពលោក គឺជាអង្គការសប្បុរសដើម្បីអភិវឌ្ឍអន្តរជាតិរបស់ BBC ។ អង្គការប៊ីប៊ីស៊ី បំរើពិភពលោក មានគោលបំណងកាត់បន្ថយភាពក្រីក្រ និងលើកកំពស់សិទ្ធិមនុស្ស ។ ក្រុមសិក្សាស្រាវជ្រាវរបស់ ប៊ីប៊ីស៊ី បំរើពិភពលោក គឺឯកទេសខាងរៀបចំការសិក្សាស្រាវជ្រាវ ដែលផ្តល់នូវចំណេះដឹងលើតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយ និង ការប្រាស្រ័យទាក់ទងជុំវិញ បញ្ហាការអភិវឌ្ឍ ។

អាស័យដ្ឋាន : អង្គការប៊ីប៊ីស៊ី បំរើពិភពលោក, Bush House, Strand, London WC2B 4PH, UK
Tel +44 (0) 20 7557 2462 Fax +44 (0) 20 7397 1622 Email ws.trust@bbc.co.uk
គេហទំព័រ bbcworldservicetrust.org ចុះបញ្ជីលេខ ១០៧៦២៣៥